Towards Sustainable Financial Management of Cambodian Universities

# សៀវភៅ-ស

## ស្តីពីគំរូហិរញ្ញវត្ថុ សម្រាប់វិស័យអប់រំឧត្តមសិក្សាកម្ពុជា

D4.1.1

Co-funded by the Erasmus+ Programme of the European Union

## សង្ខេប

ការពង្រឹងស្វ័យភាព និងគណនេយ្យភាពហិរញ្ញវត្ថុរបស់សាកលវិទ្យាល័យសាធារណៈ គឺជាតម្រូវការចាំបាច់មួយសម្រាប់ប្រព័ន្ធអប់រំឧត្តមសិក្សាកម្ពុជា។ ក្នុងក្របខណ្ឌនៃ បរិបទនេះ ឯកសារនេះផ្តល់ជូនអនុសាសន៍នានាសម្រាប់ការកែលម្អ និងការធ្វើសុខដុមនីយកម្មគំរូហិរញ្ញវត្ថុ និងការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុនៅកម្ពុជា។

## ពាក្យគន្លឹះ

ការគ្រប់គ្រងហិរញ្ញវត្ថុ | ស្វ័យភាព | គណនេយ្យភាព

## សេចក្តីជូនដំណឹងផ្លូវច្បាប់

ឯកសារនេះត្រូវបានបង្កើតឡើង និងកែសម្រួលដោយគ្រឹះស្ថានដៃគូរបស់គម្រោង Erasmus+ project BALANCE "ឆ្ពោះទៅរកការគ្រប់គ្រងហិរញ្ញវត្ថុដោយចីរភាពនៅតាមសាកលវិទ្យាល័យនៅកម្ពុជា" ស្ថិតក្រោមការសម្របសម្រួលរបស់សាកលវិទ្យាល័យ Alicante។ លទ្ធផល ទស្សនៈ និងគំនិតយោបល់ដែលបានបង្ហាញនៅក្នុងឯកសារនេះគឺជាលទ្ធផល ទស្សនៈ និងគំនិតយោបល់របស់អ្នកនិពន្ធ ហើយគណៈកម្មការអឺរ៉ុបមិនទទួលខុសត្រូវចំពោះការប្រើប្រាស់ណាមួយដែលអាចធ្វើឡើងចេញពីព័ត៌មានដែលមាននៅក្នុងឯកសារនេះទេ។

ខ្លឹមសារទាំងអស់ដែលបង្កើតដោយគម្រោង BALANCE ត្រូវបានការពារដោយច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា ជាពិសេសសិទ្ធិចម្លង។

កែសម្រួលដោយសាកលវិទ្យាល័យ Alicante ប្រទេសអេស្ប៉ាញ

© Universidad de Alicante 2022. រក្សាសិទ្ធិគ្រប់យ៉ាង។ ការផលិតឡើងវិញអាចធ្វើទៅបានលុះត្រាតែមានការទទួលស្គាល់ពីប្រភពដើមឯកសារ។

## ព័ត៌មានទំនាក់ទំនង៖

ការិយាល័យគ្រប់គ្រងគម្រោងអន្តរជាតិ (OGPI) - សាកលវិទ្យាល័យ Alicante

គេហទំព័រ៖ www.ogpi.ua.es

គេហទំព័រគម្រោង BALANCE៖ www.balance-project.eu

# មាតិកា


បញ្ជីអក្សរកាត់ .......... 3

១

សេចក្តីណែនាំគម្រោង BALANCE .......... 4

២

ប្រព័ន្ធអប់រំឧត្តមសិក្សាកម្ពុជា .......... 8

៣

គោលគំនិតសំខាន់ៗនៅក្នុងគំរូគ្រប់គ្រងហិរញ្ញវត្ថុ .......... 11

៤

បញ្ហាប្រឈមសំខាន់ៗក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនៃប្រព័ន្ធអប់រំឧត្តមសិក្សាកម្ពុជា .......... 14

៥

សំណើគំរូហិរញ្ញវត្ថុសម្រាប់ប្រព័ន្ធអប់រំឧត្តមសិក្សានៅកម្ពុជា .......... 18

៦

សេចក្តីសន្និដ្ឋាន .......... 27

ឯកសារយោង .......... 29


Co-funded by the Erasmus+ Programme of the European Union

# បញ្ជីអក្សរកាត់

ARA ....... កិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ

CDRI ...... វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

CHEA..... សមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា

DGHE .... អគ្គនាយកដ្ឋានឧត្តមសិក្សា

FM ......... ការគ្រប់គ្រងហិរញ្ញវត្ថុ

FMIS ...... ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ

GDP ....... ផលិតផលក្នុងស្រុកសរុប

HE.......... ការអប់រំឧត្តមសិក្សា

HEI......... គ្រឹះស្ថានឧត្តមសិក្សា

HERM .... ផែនទីបង្ហាញផ្លូវឧត្តមសិក្សា

MEF ....... ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

MoEYS... ក្រសួងអប់រំ យុវជន និងកីឡា

PAI......... គ្រឹះស្ថានរដ្ឋបាលសាធារណៈ

RCC....... ក្រុមប្រឹក្សាសាកលវិទ្យាធិការនៃកម្ពុជា

R&I ........ ការស្រាវជ្រាវ & នវានុវត្តន៍

STEM..... វិទ្យាសាស្រ្ត បច្ចេកវិទ្យា វិស្វកកម្ម និងគណិតវិទ្យា

# ១

# សេចក្តីណែនាំគម្រោង BALANCE

គម្រោង BALANCE (ឆ្ពោះទៅរកការគ្រប់គ្រងហិរញ្ញវត្ថុដោយចីរភាពនៅតាមសាកលវិទ្យាល័យកម្ពុជា) គឺជាគម្រោងកសាងសមត្ថភាពដែលផ្តល់មូលនិធិដោយសហភាពអឺរ៉ុប (កម្មវិធី Erasmus+ programme, 598669-EPP-1-2018-1-ES-EPPKA2-CBHE-SP)។

គម្រោង BALANCE បង្កើតឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាដោយសម្ព័ន្ធគ្រឹះស្ថានជាដៃគូដែលមានស្ថាប័នចំនួន១២ ក្នុងប្រទេសកម្ពុជា រួមជាមួយនឹងសាកលវិទ្យាល័យអឺរ៉ុបចំនួន២ដូចខាងក្រោម៖

1. ក្រសួងអប់រំ យុវជន និងកីឡា (MoEYS)
2. វិទ្យាស្ថានជាតិអប់រំ (NIE)
3. សាកលវិទ្យាល័យជាតិគ្រប់គ្រង (NUM)
4. សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP)
5. សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA)
6. សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ (UHST)
7. សាកលវិទ្យាល័យជាតិបាត់ដំបង (NUBB)
8. សាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ (NUCK)
9. សាកលវិទ្យាល័យជាតិមានជ័យ (NMU)
10. សាកលវិទ្យាល័យស្វាយរៀង (SRU)
11. វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល (KCIT)
12. វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ (KSIT)
13. សាកលវិទ្យាល័យ Alicante (UA) ប្រទេសអេស្ប៉ាញ
14. សាកលវិទ្យាល័យ Genova (UniGe) ប្រទេសអ៊ីតាលី

# BALANCE

Towards Sustainable Financial Management of Cambodian Universities




Co-funded by the Erasmus+ Programme of the European Union

គម្រោង BALANCE ត្រូវបានសហផ្តល់ហិរញ្ញប្បទានដោយគណៈកម្មាការអឺរ៉ុបតាមរយៈកម្មវិធី Erasmus+ Programe ស្ថិតក្រោមលេខកិច្ចសន្យា 598669-EPP-1-2018-1-ES-EPPKA2-CBHE-SP។ ការគាំទ្ររបស់គណៈកម្មការអឺរ៉ុបសម្រាប់ការផលិតឯកសារនេះ មិនមែនបង្កើតបានជាការអនុម័តខ្លឹមសារ ដែលឆ្លុះបញ្ចាំងពីទស្សនៈរបស់អ្នកនិពន្ធនោះទេ ហើយគណៈកម្មការអឺរ៉ុបមិនទទួលខុសត្រូវចំពោះការប្រើប្រាស់ណាមួយដែលអាចធ្វើឡើងចេញពីព័ត៌មានដែលមាននៅក្នុងឯកសារនេះទេ។

គោលបំណងសំខាន់នៃគម្រោង BALANCE គឺដើម្បីពង្រឹងស្វ័យភាព និងគណនេយ្យភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានឧត្តមសិក្សា (HEI) នៅកម្ពុជា តាមរយៈការធ្វើទំនើបកម្មការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុ (FM) និងក្របខណ្ឌច្បាប់នានា។

គោលបំណងនេះនឹងត្រូវសម្រេចបានតាមរយៈការសម្រេចបាននូវវត្ថុបំណងលម្អិតដូចខាងក្រោម៖

- លើកកម្ពស់ការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុរបស់មនុស្ស និងស្ថាប័ននៅក្នុងគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាតាមរយៈការកសាងសមត្ថភាព និងការផ្លាស់ប្តូរបទពិសោធន៍។

- បង្កើតវេទិកាទំនាក់ទំនងប្រកបដោយនិរន្តរភាពរវាងគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា និងក្រសួងពាក់ព័ន្ធ (ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ក្នុងគោលដៅកែលម្អតម្លាភាព និងការរៀបចំជាប្រព័ន្ធនៃការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុ ក៏ដូចជាការអនុវត្តគោលនយោបាយ និងនីតិវិធីរបស់គ្រឹះស្ថាន។

គម្រោង BALANCE គិតគូរពីភាពជាក់លាក់របស់គ្រឹះស្ថានដៃគូក្នុងគម្រោង ហើយត្រូវបានរៀបចំឡើងដើម្បីលើកទឹកចិត្តដៃគូកម្ពុជានីមួយៗឱ្យប្រើប្រាស់លទ្ធផលសិក្សានិងបទពិសោធន៍ដែលទទួលបានតាមរយៈសកម្មភាពគម្រោង ស្របតាមបរិបទស្ថាប័នផ្ទាល់របស់ពួកគេ។

វិធីសាស្ត្ររបស់គម្រោងព្យាករណ៍ពីលទ្ធផលរបស់សកម្មភាពនីមួយៗសម្រាប់ធ្វើជាកត្តាកំណត់សម្រាប់ដំហានបន្ទាប់ ហើយត្រូវបានរៀបចំដូចខាងក្រោម៖

- ការវិភាគអំពីការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុ។
- ការពង្រឹងសមត្ថភាពមនុស្ស និងជំនាញរបស់សមាជិកគម្រោងក្នុងប្រទេសកម្ពុជាក្នុង ការគ្រប់គ្រងហិរញ្ញវត្ថុ។
- ការធ្វើទំនើបកម្មអង្គភាពគ្រប់គ្រងហិរញ្ញវត្ថុ និងការអភិវឌ្ឍផែនការសកម្មភាពដើម្បីកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុ។
- ការធ្វើសុខដុមនីយកម្មការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងប្រព័ន្ធអប់រំឧត្តមសិក្សាសាធារណៈកម្ពុជា។

លទ្ធផលមួយក្នុងចំណោមលទ្ធផលនានារបស់គម្រោង BALANCE គឺការព្រាង **សៀវភៅ-ស** ស្តីពី *គំរូហិរញ្ញវត្ថុសម្រាប់ប្រព័ន្ធអប់រំឧត្តមសិក្សាសាធារណៈកម្ពុជា*។ ឯកសារនេះនឹងផ្តល់ជូនអនុសាសន៍មួយចំនួនសម្រាប់ការកែលម្អ និងការធ្វើសុខដុមនីយកម្មគំរូហិរញ្ញវត្ថុ និងការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា។ ឯកសារនេះត្រូវបានបង្កើតឡើងដោយផ្អែកលើការពិនិត្យឡើងវិញនូវឯកសារដែលមានស្រាប់ទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងទិន្នន័យដែលប្រមូលបានពីដៃគូសហការទាំងអស់ ក៏ដូចជាពីស្ថាប័នផ្សេងទៀតដែលមិនមែនជាដៃគូផងដែរ។ សៀវភៅ-ស នេះត្រូវបានពិភាក្សាជាសាធារណៈក្នុងសន្និសីទថ្នាក់ជាតិដែលរៀបចំដោយសមាជិកគម្រោង BALANCE ក្នុងខែមីនា និងវិច្ឆិកា ឆ្នាំ២០២២។ ដើម្បីធ្វើឱ្យឯកសារនេះកាន់តែមានភាពទូលំទូលាយ និងស្របជាមួយនឹងការអភិវឌ្ឍចុងក្រោយបំផុតនៃការអប់រំឧត្តមសិក្សានៅកម្ពុជា ជាពិសេសតាមរយៈអន្តរាគមន៍របស់គម្រោងកែលម្អការអប់រំឧត្តមសិក្សា (HEIP) កិច្ចប្រជុំអ្នកជំនាញស្តីពីសៀវភៅ-សត្រូវបានធ្វើឡើងនៅថ្ងៃទី០៨ ដល់ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ ដើម្បីពិនិត្យ ផ្តល់មតិកែលម្អបន្ថែម និងធ្វើការកែសម្រួលចាំបាច់ទៅលើខ្លឹមសារនៃសៀវភៅ-សនេះ។

Co-funded by the Erasmus+ Programme of the European Union

# ២

# ប្រព័ន្ធអប់រំឧត្តមសិក្សាកម្ពុជា

សង្គ្រាមស៊ីវិលពីចុងទសវត្សរ៍ឆ្នាំ១៩៦០ និងសម័យខ្មែរក្រហម (១៩៧៥-១៩៧៩) បានបំផ្លិចបំផ្លាញប្រព័ន្ធអប់រំកម្ពុជា។ បន្ទាប់ពីការដួលរលំរបបខ្មែរក្រហមនៅឆ្នាំ១៩៧៩ បើទោះបីជាប្រទេសកម្ពុជានៅតែជួបប្រទះសង្គ្រាមស៊ីវិលមួយផ្សេងទៀតដែលទើបតែឈានដល់ទីបញ្ចប់នៅចុងទសវត្សរ៍ឆ្នាំ១៩៩០ក៏ដោយ ក៏រដ្ឋាភិបាលបានចាប់ផ្តើមកសាងប្រព័ន្ធអប់រំឡើងវិញដោយផ្តោតជាបឋមលើការអប់រំចំណេះទូទៅ។ នៅឆ្នាំ១៩៩៧ រដ្ឋាភិបាលបានចាប់ផ្តើមធ្វើឯកជនភាវូបនីយកម្មការអប់រំឧត្តមសិក្សា ដោយផ្អែកលើគោលការណ៍ភាពជាដៃគូសាធារណៈនិងឯកជន ដែលបានអនុញ្ញាតឱ្យបើកដំណើរការគ្រឹះស្ថានឧត្តមសិក្សាឯកជន ក៏ដូចជាការដាក់ដំណើរការលំនាំបង់ថ្លៃសិក្សានៅក្នុងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ។

ឯកជនភាវូបនីយកម្មឧត្តមសិក្សា បាននាំឱ្យមានការកើនឡើងនូវចំនួនគ្រឹះស្ថានឧត្តមសិក្សា(HEI) ពីចំនួន១៤ ក្នុងឆ្នាំ២០០០ ដល់១៣០ (គ្រឹះស្ថានឧត្តមសិក្សាឯកជនមានចំនួន៨២) ក្នុងឆ្នាំ២០២២ ដែលមាននៅក្នុង២០ខេត្តនិងរាជធានី។ គ្រឹះស្ថានឧត្តមសិក្សាទាំង១៣០នេះ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងចំនួន១៦ ដែលក្នុងនោះក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ទទួលបន្ទុកគ្រឹះស្ថានឧត្តមសិក្សាចំនួន៨២។ ទាក់ទងនឹងការចុះឈ្មោះចូលរៀននៅកម្រិតអប់រំឧត្តមសិក្សា ចំនួននិស្សិតបានកើនឡើងពីប្រហែល ១០.០០០នាក់នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ដល់ប្រហែល ២០០.០០០នាក់ ក្នុងឆ្នាំ២០២១។ អត្រាចុះឈ្មោះចូលរៀននៅឧត្តមសិក្សាមានត្រឹមតែប្រហែល ១១% ក្នុងឆ្នាំ២០១៧ ហើយទោះបីជាអត្រាចុះឈ្មោះចូលរៀនត្រូវបានព្យាករណ៍ថានឹងមានប្រហែល ១៦% ក្នុងឆ្នាំសិក្សា២០២២/២០២៣នេះក្តី ក៏អត្រានេះនៅតែទាបខ្លាំងបើប្រៀបធៀបទៅនឹងអត្រាក្នុងប្រទេសដទៃទៀតជាសមាជិកអាស៊ាន។

ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស គឺជាកត្តាសំខាន់សម្រាប់ប្រទេសកម្ពុជា ដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់ខ្លួន ក្នុងការប្រែក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដូច្នេះហើយ ការខិតខំប្រឹងប្រែងជាច្រើនត្រូវបានធ្វើឡើងចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ២០១០ លើការធ្វើកំណែទម្រង់ និងការធ្វើឱ្យប្រសើរឡើងនូវការអបរំឧត្តមសិក្សានៅកម្ពុជា។ យោងតាមយុទ្ធសាស្ត្រអនុវិស័យការអប់រំឧត្តមសិក្សាឆ្នាំ ២០២១-២០៣០ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់នូវបេសកកម្មសំខាន់ៗចំនួនពីរ៖ ១) ជានាកំណើនចំនួននិស្សិតដែលមានសមត្ថភាពខ្ពស់ដើម្បីឆ្លើយតបទៅនឹងទីផ្សារការងារ និង ២) ជានាកំណើនចំនួនការស្រាវជ្រាវអនុវត្តន៍ ដែលត្រូវបានផ្សារភ្ជាប់និងឆ្លើយតបទៅនឹងការអភិវឌ្ឍ។

ថ្មីៗនេះ អន្តរាគមន៍របស់គម្រោងឧត្តមសិក្សា ជាទូទៅផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវការបង្រៀន និងការរៀន និងការលើកកម្ពស់ការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) និងកសិកម្ម។ អន្តរាគមន៍ទាំងនេះត្រូវបានរំពឹងថានឹងដោះស្រាយបញ្ហាគុណភាពអប់រំ

កម្រិតឧត្តមសិក្សា និងភាពពាក់ព័ន្ធ។ សារៈសំខាន់ដូចគ្នានេះដែរគឺតម្រូវការក្នុងការដោះស្រាយបញ្ហាប្រឈមខាងផ្នែកប្រសិទ្ធភាពអភិបាលកិច្ច រដ្ឋបាល និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ ការធ្វើឱ្យប្រសើរឡើងនូវធនធានមនុស្ស និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុមានសារៈសំខាន់ណាស់ ដើម្បីធានាបានស្ថិរភាព គណនេយ្យភាព តម្លាភាព និងនិរន្តរភាពហិរញ្ញវត្ថុ។ ដូច្នេះ សៀវភៅ-សស្ដីពីគំរូហិរញ្ញវត្ថុសម្រាប់អនុវិស័យអប់រំឧត្តមសិក្សាកម្ពុជា នឹងចូលរួមចំណែកយ៉ាងច្រើនដល់ការធ្វើសុខដុមនីយកម្មការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុ ហើយវាជាជំហានដ៏សំខាន់មួយឆ្ពោះទៅរកការធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ច និងស្វ័យភាពនៅក្នុងការអប់រំឧត្តមសិក្សាកម្ពុជា។

# ៣

# គោលគំនិតសំខាន់ៗនៅក្នុងគំរូគ្រប់គ្រងហិរញ្ញវត្ថុ

ខាងក្រោមនេះ គឺជាគោលគំនិតសំខាន់ៗមួយចំនួនដែលប្រើក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនៅកម្រិតឧត្តមសិក្សា៖

- **តម្លាភាព** និង **គណនេយ្យភាព** នៃការគ្រប់គ្រងហិរញ្ញវត្ថុនៅកម្រិតឧត្តមសិក្សា គឺមានជាប់ទាក់ទងទៅនឹង៖ ១) ការចូលរួមយ៉ាងសកម្មរបស់សហគមន៍ក្នុងការរៀបចំ/ការអនុម័តថវិកា ២) មានថវិកាលម្អិត (រួមទាំងថ្លៃចំណាយតាមខ្ទង់) និងមូលហេតុចំណាយត្រឹមត្រូវ និង ៣) ភាពអាចរកបាននៃព័ត៌មាននេះតាមរយៈគេហទំព័រ និង/ឬបណ្តាញទំនាក់ទំនងផ្ទៃក្នុង។
- **ស្វ័យភាពស្ថាប័ន** គឺជាសមត្ថភាពរបស់គ្រឹះស្ថានឧត្តមសិក្សា ក្នុងការរៀបចំរចនាសម្ព័ន្ធផ្ទៃក្នុង ជ្រើសរើសនិងបណ្តុះបណ្តាលបុគ្គលិក រៀបចំកម្មវិធីសិក្សា និងប្រើប្រាស់ធនធានហិរញ្ញវត្ថុស្របតាមបេសកកម្ម និងទម្រង់ជាក់លាក់របស់ស្ថាប័នពួកគេ។
- **ការបែងចែកធនធាន**នៅកម្រិតឧត្តមសិក្សា អាចមានប្រសិទ្ធភាពនៅពេលដែលមូលនិធិនានាត្រូវបានដាក់ចូលទៅក្នុងកម្មវិធីដែលជួយឱ្យគ្រឹះស្ថានឧត្តមសិក្សាសម្រេចបានបេសកកម្មសិក្សារបស់ពួកគេ។ ដំណើរការបែងចែកធនធានប្រកបដោយប្រសិទ្ធភាព អាចបណ្តាលឱ្យមានការចែករំលែកព័ត៌មាននៅទូទាំងមហាវិទ្យាល័យ និងដេប៉ាតឺម៉ង់នានា ដែលអាចជួយឱ្យការសម្រេចចិត្តកាន់តែប្រសើរឡើង និងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពជាងមុន។
- គំរូផ្តល់មូលនិធិរបស់សាកលវិទ្យាល័យមានការផ្លាស់ប្តូរយ៉ាងខ្លាំង ដែលនាំឱ្យគ្រឹះស្ថានសិក្សាត្រូវស្វែងរក និងរៀបចំយុទ្ធសាស្ត្រធក់យកកាលានុវត្តភាពថ្មីៗ ដើម្បី**បង្កើតប្រាក់ចំណូល** ជាជាងពឹងផ្អែកតែលើប្រាក់ចំណូលដែលបានមកពីការបង់ថ្លៃសិក្សា។ គ្រឹះស្ថានឧត្តមសិក្សាកំពុងងាកកាន់តែខ្លាំងឆ្ពោះទៅរកលំហូរប្រាក់ចំណូលពីប្រភពផ្សេងៗ ដូចជាមូលនិធិជំនួយការបរិច្ចាគឯកជនការបោះពុម្ពផ្សាយបម្រើអតិថិជន ការផ្តល់និងលក់ប៉ាតង់ វគ្គសិក្សាសម្រាប់ថ្នាក់ក្រោយបរិញ្ញាបត្រដែលអាចរកប្រាក់ចំណេញបាននិងមធ្យោបាយផ្សេងៗទៀត។
- ការងារ**គ្រប់គ្រងមូលនិធិអាហារូបករណ៍** គឺជាដំណើរការដ៏ស៊ីជម្រៅ និងស្មុគស្មាញមួយ។ ការកំណត់លក្ខណៈវិនិច្ឆ័យជ្រើសរើស ការស្វែងរកអ្នកដាក់ពាក្យសុំ ការពិនិត្យមើលពាក្យសុំរបស់ពួកគេ និងការរាយការណ៍លទ្ធផល គឺគ្រាន់តែជាកិច្ចការមួយចំនួនប៉ុណ្ណោះដែលអ្នកគ្រប់គ្រងមូលនិធិអាហារូបករណ៍ ត្រូវបានគេរំពឹងថានឹងសម្រេចបានក្នុងការគាំទ្រដល់និស្សិត ដែលស័ក្តិសមនឹងទទួលបានអាហារូបករណ៍ និងបង្កើនឱ្យបានដល់កម្រិតអតិបរមានូវផលជះនៃមូលនិធិ។
- **គម្រោងប្រាក់កម្ចី**ទទួលបានចំណាប់អារម្មណ៍ជាពិសេសពីអ្នកបង្កើតគោលនយោបាយ

ព្រោះវាអាចចូលរួមចំណែកដោះស្រាយបញ្ហាគោលនយោបាយជាច្រើនដែលកំពុងរងសម្ពាធដែលរដ្ឋាភិបាលនានាកំពុងជួបប្រទះ។ គម្រោងទាំងនេះអាចជួយសម្រាលសម្ពាធលើថវិកាជាតិតាមរយៈការជួយសម្រួលដល់ការចែករំលែកការចំណាយធំៗ បណ្តាលមកពីការដំឡើងថ្លៃសិក្សា និងកម្រៃសេវាផ្សេងៗនៅសាកលវិទ្យាល័យ។

**គំរូគ្រប់គ្រងហិរញ្ញវត្ថុក្នុងវិស័យអប់រំឧត្តមសិក្សា មានបង្ហាញជូននៅក្នុងរូបខាងក្រោម៖**



# ៤

# បញ្ហាប្រឈមសំខាន់ៗ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនៃប្រព័ន្ធអប់រំឧត្តមសិក្សាកម្ពុជា

**កំណែទម្រង់នានារបស់រដ្ឋាភិបាល** ដើម្បីកែលម្អការអប់រំឧត្តមសិក្សានោះ បានចាប់ផ្តើមនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ ដោយអនុញ្ញាតឱ្យវិស័យឯកជនចូលរួមក្នុងការផ្តល់សេវាអប់រំកម្រិតឧត្តមសិក្សា។ កំណែទម្រង់មួយដ៏គួរឱ្យចាប់អារម្មណ៍ផងដែរនោះ គឺការប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈទៅជាគ្រឹះស្ថានរដ្ឋបាលសាធារណៈ (PAI)។ បន្ទាប់ពីមានវិធានការនេះ ទីភ្នាក់ងារនិងស្ថាប័នសាធារណៈនានាអាចផ្លាស់ប្តូរទៅជាទីភ្នាក់ងារ ឬ ស្ថាប័នស្វយ័ត។

ក្នុងឆ្នាំ២០១៧ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើត**គោលនយោបាយជាតិស្តីពីអភិបាលកិច្ច និងហិរញ្ញវត្ថុការអប់រំឧត្តមសិក្សា** ដែលបានផ្តល់អនុសាសន៍អំពីវិធានការសំខាន់ៗចំនួន១០ ដើម្បីកែលម្អអភិបាលកិច្ច និងហិរញ្ញវត្ថុនៅឧត្តមសិក្សាសាធារណៈ។ វិធានការចំនួន៥ ក្នុងចំណោមវិធានការទាំងនេះ មានការទាក់ទងនឹងហិរញ្ញវត្ថុអប់រំឧត្តមសិក្សា៖

- ដំឡើងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុដែលអាចទុកចិត្តបាន និងការត្រួតពិនិត្យផ្ទៃក្នុងដ៏រឹងមាំនៅគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ។
- បង្កើន និងកែលម្អថវិការដ្ឋសម្រាប់ប្រព័ន្ធអប់រំឧត្តមសិក្សា។
- ផ្តល់មូលនិធិរដ្ឋក្នុងទម្រង់ជាកញ្ចប់ជំនួយ។
- អនុញ្ញាតឱ្យគ្រឹះស្ថានឧត្តមសិក្សាសាធារណៈកំណត់ថ្លៃសិក្សាដោយឡែកៗពីគ្នា រួមជាមួយនឹងការលើកលែងការបង់ថ្លៃសិក្សាពីរដ្ឋ និងការផ្តល់មូលនិធិដោយរដ្ឋ។ និង
- បង្កើនការផ្តល់មូលនិធិរដ្ឋទៅលើការស្រាវជ្រាវ និងនវានុវត្តន៍ ហើយមូលនិធិនោះត្រូវផ្តល់ឱ្យដោយផ្អែកលើការប្រកួតប្រជែង និងទៅតាមប្រភេទនៃការស្រាវជ្រាវ។

ថ្មីៗនេះ ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័ត**យុទ្ធសាស្ត្រអនុវិស័យអប់រំឧត្តមសិក្សាកម្ពុជាឆ្នាំ២០២១-២០៣០** ដែលមានគោលបំណងលើកកម្ពស់វិស័យអប់រំឧត្តមសិក្សាផងដែរ។

ទោះជាយ៉ាងណា លទ្ធផលកំណែទម្រង់ត្រូវការពេលវេលា។ ការសិក្សាមួយចំនួនរកឃើញបញ្ហានៅក្នុងផ្នែកសំខាន់ចំនួនពីរ ហើយបញ្ហាទាំងនោះក៏ត្រូវបានបញ្ជាក់ផងដែរដោយគ្រឹះស្ថានដៃគូនៃគម្រោង BALANCE ៖

### អភិបាលកិច្ចការអប់រំឧត្តមសិក្សាសាធារណៈ៖

- កង្វះក្របខណ្ឌច្បាប់សមស្រប ដែលអាចគាំទ្រគោលនយោបាយពាក់ព័ន្ធជាពិសេសសម្រាប់វិស័យអប់រំឧត្តមសិក្សា។
- ប្រព័ន្ធអប់រំកម្រិតឧត្តមសិក្សាមានភាពបែកខ្ញែក និងការសម្របសម្រួលនៅមានកម្រិតរវាង

តួអង្គផ្សេងៗ។

- ការចូលរួមរបស់ភាគីពាក់ព័ន្ធមិនស៊ីសង្វាក់គ្នា។
- តួនាទីមិនសូវជាសំខាន់របស់ក្រុមប្រឹក្សាភិបាល។
- ការចូលរួមរបស់សិក្សាធិការនៅទន់ខ្សោយ។
- សមត្ថភាពមនុស្ស និងស្ថាប័ននៅមានកម្រិតទាបក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ។
- ស្វ័យភាព និងគណនេយ្យភាពរបស់ស្ថាប័នមានតិចតួច។
- កង្វះតម្លាភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនៅគ្រឹះស្ថានឧត្តមសិក្សា។

**ហិរញ្ញវត្ថុរបស់ការអប់រំឧត្តមសិក្សាសាធារណៈ៖**

- យន្តការហិរញ្ញប្បទានមិនមានភាពបត់បែន និងចាស់គំរឹល។
- ការវិនិយោគមិនគ្រប់គ្រាន់លើឧត្តមសិក្សា និងលើសកម្មភាពស្រាវជ្រាវ និង នវានុវត្តន៍។
- ការពឹងផ្អែកតែលើថ្លៃសិក្សា។
- ការគាំទ្រដល់និស្សិតនៅពុំទាន់មានរបៀបរៀបរយ (អាហារូបករណ៍ ប្រាក់កម្ចីនិស្សិត និង ការឧបត្ថម្ភធន)។
- យន្តការហិរញ្ញវត្ថុស្ថាប័នមានភាពផុយស្រួយ និងមិនមានតម្លាភាព។
- យន្តការចំណាយយឺតយ៉ាវ និងការិយាធិបតេយ្យ។

# ដើមឈើបញ្ហា
## បញ្ហាចម្បងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនៃប្រព័ន្ធអប់រំឧត្តមសិក្សាកម្ពុជា



# ៥

# សំណើគំរូហិរញ្ញវត្ថុសម្រាប់ប្រព័ន្ធអប់រំឧត្តមសិក្សាកម្ពុជា

គ្រឹះស្ថានដៃគូនៃគម្រោង BALANCE បានប្រើប្រាស់ឯកសារស៊េរីលេខ១១៥ របស់ CDRI ស្តីពីហិរញ្ញវត្ថុក្នុងការអប់រំឧត្តមសិក្សាសាធារណៈនៅកម្ពុជា (ឆ្នាំ២០១៩) ជាឯកសារយោង ដើម្បីកំណត់បញ្ហាប្រឈមសំខាន់ៗ នៃការគ្រប់គ្រងហិរញ្ញវត្ថុក្នុងការអប់រំឧត្តមសិក្សានៅកម្ពុជា ហើយក៏ដើម្បីស្នើចេញជាអនុសាសន៍ផងដែរ។ បញ្ហាប្រឈមនានាត្រូវបានពិភាក្សានៅក្នុងសកម្មភាពមួយចំនួនរបស់គ្រឹះស្ថានដៃគូនៃគម្រោង (សិក្ខាសាលា សន្និសីទ ។ល។) ហើយរូប/តារាងខាងក្រោមបានសង្ខេបអំពីបញ្ហា/បញ្ហាប្រឈម អនុសាសន៍ និងសំណើជាក់លាក់តាម រយៈឧទាហរណ៍ ឬការអនុវត្តល្អៗនានា។

.

# អភិបាលកិច្ចនៃការអប់រំឧត្តមសិក្សាសាធារណៈ

| បញ្ហា / បញ្ហាប្រឈម | អនុសាសន៍ | ឧទាហរណ៍ / ការអនុវត្តល្អ |
|---|---|---|
| កង្វះក្របខណ្ឌច្បាប់សម-ស្របដែលអាចគាំទ្រគោលនយោបាយពាក់ព័ន្ធនានាជាពិសេស សម្រាប់វិស័យអប់រំឧត្តមសិក្សា | - អនុម័តគោលនយោបាយដាក់លាក់សម្រាប់ការអប់រំឧត្តមសិក្សា។<br>- អនុវត្ត និងតាមដានលទ្ធ-ផលយុទ្ធសាស្ត្រអនុវិស័យអប់រំឧត្តមសិក្សាកម្ពុជាឆ្នាំ ២០២១-២០៣០។<br>- អនុម័តក្របខណ្ឌគោលនយោបាយជាពិសេសមួយសម្រាប់ស្វ័យភាពសាកលវិទ្យាល័យនៅកម្ពុជា។ | - បង្កើតបទប្បញ្ញត្តិ គោលការណ៍ណែនាំ យន្តការជាក់លាក់សម្រាប់ប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាទៅជាគ្រឹះស្ថានរដ្ឋបាលសាធារណៈដែលមានឧបករណ៍វិមជ្ឈការសម្រាប់សិក្សាធិការ បុគ្គលិក និងការគ្រប់គ្រងហិរញ្ញវត្ថុ។ |
| ប្រព័ន្ធអប់រំឧត្តមសិក្សាមានភាពបែកខ្ញែក និងការសម្របសម្រួលមានកម្រិតរវាងតួអង្គផ្សេងៗគ្នា | - បង្កើតស្ថាប័នសម្របសម្រួលថ្នាក់ជាតិមួយដែលអាចមានចក្ខុវិស័យពេញលេញអំពីប្រព័ន្ធអប់រំឧត្តមសិក្សា ហើយស្នើឱ្យមានសកម្មភាពជាក់លាក់។ | - ការបង្កើតឧត្តមក្រុមប្រឹក្សាជាតិអប់រំ ដូចដែលបានបង្ហាញនៅក្នុងច្បាប់អប់រំ។ ក្រុមប្រឹក្សាសាកលវិទ្យាធិការនៃកម្ពុជា (RCC) និងសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា (CHEA) អាចដើរតួជាស្ថាប័នគាំទ្រ។ |
| ការចូលរួមរបស់ភាគីពាក់ព័ន្ធមិនស៊ីសង្វាក់គ្នានៅក្នុងគោលនយោបាយ និងការធ្វើសេចក្តី សម្រេចចិត្ត។ | - បង្កើនការចូលរួមរបស់សមាគមនិស្សិត និងតួអង្គសាកលវិទ្យាល័យផ្សេងទៀតក្នុងការបង្កើតគោល | - បង្កើតកៅអីសម្រាប់អ្នកតំណាងរបស់សមាគមនិស្សិតសមាជិក អង្គការសង្គមស៊ីវិលនិងវិស័យឧស្សាហកម្ម/ឯកជននៅក្នុងស្ថាប័នអភិបាលកិច្ចរបស់សាកលវិទ្យាល័យ(ដូច |

| បញ្ហា / បញ្ហាប្រឈម | អនុសាសន៍ | ឧទាហរណ៍ / ការអនុវត្តល្អ |
|---|---|---|
| | នយោបាយ និងការសម្រេចចិត្ត។ | នៅសាកលវិទ្យាល័យនានានៅសហភាពអឺរ៉ុបជាដើម)។ |
| តួនាទីមិនសូវសំខាន់របស់ក្រុមប្រឹក្សាភិបាល | - បង្កើនតួនាទីរបស់ក្រុមប្រឹក្សាភិបាល ដោយបង្កើនសិទ្ធិអំណាចរបស់ពួកគេ និងបង្កើនការចូលរួមរបស់ពួកគេ។<br>- រៀបចំគោលការណ៍ណែនាំសម្រាប់ការជ្រើសរើស ការកំណត់មុខងារ និង ការអនុវត្តការងាររបស់ក្រុមប្រឹក្សាភិបាល។ | - គោរពតាមវិធាន និងបទប្បញ្ញត្តិដែលមានចែងក្នុងអនុក្រឹត្យ ជ្រើសរើសសមាជិកត្រឹមត្រូវ និងបញ្ជាក់យ៉ាងច្បាស់អំពីតួនាទី និងទំនួលខុសត្រូវរបស់ពួកគេ។ |
| ការចូលរួមរបស់សិក្សាធិការនៅទន់ខ្សោយ | - បង្កើតគោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រង សិក្សាធិការ និងក្រុមប្រឹក្សាសិក្សា-ធិការ។ | - ពង្រឹងតួនាទីរបស់ក្រុមប្រឹក្សាសិក្សាធិការក្នុងការគ្រប់គ្រង និងដំណើរការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ។ |
| សមត្ថភាពមនុស្សនិងស្ថាប័នក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនៅមានកម្រិតទាប។ | - គាំទ្រជំនាញវិជ្ជាជីវៈរបស់បុគ្គលិកសិក្សា និបុគ្គលិកគ្រប់គ្រង។<br>- បង្កើតគោលការណ៍ណែនាំនិងលក្ខណៈវិនិច្ឆ័យជ្រើសរើសមន្ត្រីហិរញ្ញវត្ថុ និងមន្ត្រីលទ្ធកម្ម។ | - រៀបចំសកម្មភាពកសាងសមត្ថភាពអំពីប្រធានបទពាក់ព័ន្ធនានាសម្រាប់មន្ត្រីគ្រឹះស្ថានឧត្តមសិក្សាដូចអ្វីដែលបានធ្វើនៅក្នុងគម្រោង BALANCE។ |
| ស្វ័យភាពនិងគណនេយ្យភាពរបស់ស្ថាប័ននៅគ្រឹះស្ថានឧត្តមសិក្សានៅទន់ខ្សោយ។ | - បង្កើតគោលការណ៍ណែនាំនិងលក្ខណៈវិនិច្ឆ័យជ្រើសរើសមន្ត្រីធនធានមនុស្ស។<br>- បង្កើនចំនួនគ្រឹះស្ថានរដ្ឋបាលសាធារណៈ។ | - ចែករំលែកការអនុវត្តល្អៗ រវាងគ្រឹះស្ថានឧត្តមសិក្សាដូចមគ្គុទ្ទេសក៍អនុវត្តល្អៗ របស់គម្រោង BALANCE សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុនៅគ្រឹះស្ថាន |

| បញ្ហា / បញ្ហាប្រឈម | អនុសាសន៍ | ឧទាហរណ៍ / ការអនុវត្តល្អ |
| --- | --- | --- |
| | - អនុវត្តកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ (ARA)។ | ឧត្តមសិក្សា។<br>- ផ្តល់សិទ្ធិក្នុងការធ្វើផែនការ និងគ្រប់គ្រងប្រាក់ចំណូលនៅថ្នាក់មហាវិទ្យាល័យ។ |
| កង្វះតម្លាភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនៅគ្រឹះស្ថានឧត្តមសិក្សា។ | - បង្កើនតម្លាភាពក្នុងគ្រប់ទិដ្ឋភាពហិរញ្ញវត្ថុរបស់ស្ថាប័នដោយការអនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ (FMIS)។ | - ចេញផ្សាយព័ត៌មានអំពីថវិកានៅលើគេហទំព័ររបស់សាកលវិទ្យាល័យ។ |

# ហិរញ្ញវត្ថុនៃការអប់រំឧត្តមសិក្សាសាធារណៈ

| បញ្ហា / បញ្ហាប្រឈម | អនុសាសន៍ | ឧទាហរណ៍ / ការអនុវត្តល្អ |
|---|---|---|
| យន្តការហិរញ្ញប្បទានមិនមានភាពបត់បែន និងចាស់គំរឹល | - ដាក់ចេញផែនការវិនិយោគសាធារណៈដើម្បីទាក់ទាញមូលនិធិ។<br>- ផ្តល់មូលនិធិរដ្ឋក្នុងទម្រង់ជាកញ្ចប់ជំនួយ និងផ្តល់មូលនិធិផ្អែកលើលទ្ធផលការងារ | - បន្ថែមលើការចូលរួមចំណែកជាមូលដ្ឋានរបស់រដ្ឋ ឬតំបន់រដ្ឋាភិបាលអាចកំណត់គោលដៅយុទ្ធសាស្ត្រដែលអាចមានការពាក់ព័ន្ធនឹងការផ្តល់មូលនិធិបន្ថែម។ វានឹងល្អប្រសើរប្រសិនបើការផ្តល់មូលនិធិបន្ថែមមានភាពពាក់ព័ន្ធទៅនឹងលទ្ធផលដែលទទួលបានតាមរយៈការប្រៀបធៀបដោយផ្ទាល់នៃលទ្ធផលដែលសម្រេចបានដោយគ្រឹះស្ថានឧត្តមសិក្សានីមួយៗ។<br>- ការអនុវត្តល្អៗ៖ យន្តការហិរញ្ញប្បទាន និងដំណើរការលទ្ធកម្មល្អៗរបស់កម្មវិធីវិនិយោគសាធារណៈ (PIP) ដែលបានទទួលប្រាក់កម្ចីពីធនាគារពិភពលោក។ |
| ការវិនិយោគមិនគ្រប់គ្រាន់លើវិស័យអប់រំឧត្តមសិក្សា និងលើសកម្មភាពស្រាវជ្រាវ និងនវានុវត្តន៍ | - បង្កើន និងធ្វើឱ្យប្រសើរឡើងនូវការផ្តល់មូលនិធិសាធារៈណៈសម្រាប់ការអប់រំឧត្តមសិក្សា និងការស្រាវជ្រាវនិងនវានុវត្តន៍ រួមទាំងការមូលនិធិដែលមានលក្ខណៈប្រកួតប្រជែងផងដែរ។<br>- ធ្វើឱ្យប្រសើរឡើងនូវសកម្មភាពនានាដែលអាច | - ការគាំទ្រផ្នែកហិរញ្ញវត្ថុរបស់រដ្ឋចំពោះការអនុវត្តល្អៗបំផុតអាចពង្រឹងគុណភាពប្រព័ន្ធអប់រំកម្រិតឧត្តមសិក្សាទាំងមូល។ ទម្រង់នៃការផ្តល់មូលនិធិដែលមានលក្ខណៈប្រកួតប្រជែងអាចមានភាពស័ក្តិសមទៅនឹងបរិយាកាសដែលបង្កើតឡើងដោយគ្រឹះស្ថានឧត្តមសិក្សាក្នុង |

| បញ្ហា / បញ្ហាប្រឈម | អនុសាសន៍ | ឧទាហរណ៍ / ការអនុវត្តល្អ |
|---|---|---|
| | ទាក់ទាញមូលនិធិក្នុងតំបន់និងឯកជន។ | វិសាលភាពនិងឯកទេសផ្សេងៗគ្នា។<br>- លើសពីនេះ គ្រឹះស្ថានឧត្តមសិក្សាអាចជ្រើសរើសឯកទេស និងសកម្មភាពអប់រំឧត្តមសិក្សា/ការស្រាវជ្រាវនិងនវានុវត្តន៍ដែលគួរឱ្យចាប់អារម្មណ៍ ទាំងសម្រាប់វិស័យថ្នាក់តំបន់និងវិស័យឯកជនដើម្បីទាក់ទាញការផ្តល់ហិរញ្ញប្បទានបន្ថែម។<br>- ការអនុវត្តល្អៗដែលត្រូវបានរកឃើញនៅក្នុងគ្រឹះស្ថានឧត្តមសិក្សាក្នុងស្រុកដូចជា NUCK និង MNU ដែលទាក់ទាញបានមូលនិធិសម្រាប់ការស្រាវជ្រាវនិងនវានុវត្តន៍ពីក្រុមហ៊ុនឯកជន និងម្ចាស់ជំនួយ។ |
| ការពឹងផ្អែកតែលើថ្លៃសិក្សា | - អនុញ្ញាតឱ្យគ្រឹះស្ថានឧត្តមសិក្សាសាធារណៈកំណត់ថ្លៃសិក្សាដោយឡែកៗពីគ្នា រួមជាមួយនឹងការលើកលែងការបង់ថ្លៃសិក្សាពីរដ្ឋ និងការផ្តល់មូលនិធិដោយរដ្ឋ។<br>- អាហារូបករណ៍បន្ថែម និងថ្លៃសិក្សាសម្រាប់និស្សិតពូកែអាចទទួលបានពីការបែងចែករបស់រដ្ឋាភិបាល/ភាគីពាក់ព័ន្ធ/វិនិយោគិន/ | - ការលើកលែងថ្លៃសិក្សាអាចជួយគាំទ្រដល់និស្សិតដែលមានគុណភាពខ្ពស់ និងការអប់រំឧត្តមសិក្សាឱ្យមានប្រសិទ្ធភាពជាងមុន។ គ្រឹះស្ថានឧត្តមសិក្សានីមួយៗអាចអនុម័តបទប្បញ្ញត្តិគ្រប់គ្រាន់ដើម្បីកំនត់ថ្លៃសិក្សាដោយឡែកៗពីគ្នា និងការលើកលែងថ្លៃសិក្សា និងបង្កើតគោលនយោបាយហិរញ្ញវត្ថុ |

| បញ្ហា / បញ្ហាប្រឈម | អនុសាសន៍ | ឧទាហរណ៍ / ការអនុវត្តល្អ |
|---|---|---|
| | ឧស្សាហកម្ម/ធនាគារ ។ | ប្រកបដោយប្រសិទ្ធភាព។<br>- ការអនុវត្តល្អៗ៖ សាកលវិទ្យាល័យ NUM បានអនុវត្តកម្មវិធីអាហារូបករណ៍បានបន្ថែម ពីភាគីពាក់ព័ន្ធជាច្រើនឆ្នាំមកហើយ។ |
| គម្រោងគាំទ្រនិស្សិតមិនទាន់ច្បាស់លាស់នៅថ្នាក់ជាតិ និងថ្នាក់គ្រឹះស្ថាន(អាហារូបករណ៍កម្ចីនិស្សិតនិងការឧបត្ថម្ភធន) | - បង្កើត និងអនុវត្តគម្រោងប្រាក់កម្ចីថ្នាក់ជាតិសម្រាប់និស្សិត។<br>- កៅអីអាហារូបករណ៍ទាំងនោះគួរតែត្រូវបានគ្រប់គ្រងដោយសាកលវិទ្យាល័យ និង/ឬក្រសួងអប់រំ យុវជន និងកីឡា ដើម្បីឱ្យនិស្សិតអាចទទួលបានព័ត៌មានច្បាស់លាស់អំពីអាហារូបករណ៍ដែលមាន។ | - លើកកម្ពស់លទ្ធភាពចូលរៀនដោយសមធម៌ក្នុងប្រព័ន្ធអប់រំឧត្តមសិក្សាតាមរយៈប្រព័ន្ធអាហារូបករណ៍ ដែលអាចផ្តល់អាទិភាពដល់និស្សិតមកពីគ្រួសារដែលមានប្រាក់ចំណូលទាប។ |
| ដំណើរការហិរញ្ញវត្ថុស្ថាប័នមានភាពផុយស្រួយ | - បង្កើត និងអនុវត្តគ្រឹះស្ថានរដ្ឋបាលសាធារណៈនិងប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ។ | - អនុម័តបទប្បញ្ញត្តិផ្ទៃក្នុងដើម្បីធានាឱ្យមានការទទួលខុសត្រូវ និងតម្លាភាពចំពោះនីតិវិធីហិរញ្ញវត្ថុ។<br>- ធ្វើឌីជីថលនីយកម្មដំណើរការចំណាយដែលពាក់ព័ន្ធទាំងអស់។<br>- សកម្មភាពកសាងសមត្ថភាពសម្រាប់ភាគីពាក់ព័ន្ធទាំងអស់អាចផ្តល់តម្លៃបន្ថែមដ៏គួរឱ្យចាប់អារម្មណ៍។. |

| បញ្ហា / បញ្ហាប្រឈម | អនុសាសន៍ | ឧទាហរណ៍ / ការអនុវត្តល្អ |
|---|---|---|
| យន្តការចំណាយយឺតយ៉ាវ និងការិយាល័យធិបតេយ្យ | - ដំឡើងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុដែលអាចទុកចិត្តបាន និងការគ្រប់គ្រងផ្ទៃក្នុងដ៏រឹងមាំ | - ធ្វើឌីជីថលនីយកម្មលើនីតិវិធីហិរញ្ញវត្ថុតាមរបៀបដូចគ្នាទៅនឹងវិធីដែលដាក់ដំណើរការដោយក្រសួងសាធារណការ និងដឹកជញ្ជូន។ ឧទាហរណ៍មួយទៀតគឺក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងពាណិជ្ជ-កម្ម ដែលក្រសួងទាំងនេះមាននីតិវិធីឌីជីថល។ |

# ៦

# សេចក្ដីសន្និដ្ឋាន

សៀវភៅ-ស ស្តីពីគំរូហិរញ្ញវត្ថុសម្រាប់ការអប់រំឧត្តមសិក្សាកម្ពុជា គឺជាឯកសារទស្សនទានគោលនយោបាយមួយដែលមានគោលបំណង៖

- កំណត់ និងបញ្ជាក់អំពីបញ្ហា និងបញ្ហាប្រឈមសំខាន់ៗនៃប្រព័ន្ធអប់រំឧត្តមសិក្សា កម្ពុជា ទាក់ទងនឹងអភិបាលកិច្ច និងហិរញ្ញវត្ថុរបស់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ។
- ផ្តល់អនុសាសន៍ដោយផ្អែកលើបទពិសោធន៍របស់សហភាពអឺរ៉ុប (EU) ឬបទពិសោធន៍នៅក្នុងស្រុក។ និង
- ណែនាំការអនុវត្តល្អៗសម្រាប់ចំណុចបញ្ហាដែលបានកំណត់នីមួយៗ។

ឯកសារនេះអាចមានប្រយោជន៍សម្រាប់អ្នកបង្កើតគោលនយោបាយ និងថ្នាក់ដឹកនាំគ្រឹះស្ថានឧត្តមសិក្សាក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ ដើម្បីធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ច ការគ្រប់គ្រង និងរដ្ឋបាលនៃការអប់រំឧត្តមសិក្សាតាមរយៈកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ។ ឯកសារនេះអាចជាឯកសារយោងមួយសម្រាប់គ្រឹះស្ថានឧត្តមសិក្សា ដើម្បីបង្កើតសៀវភៅណែនាំ/គោលការណ៍ណែនាំអំពីការគ្រប់គ្រងហិរញ្ញវត្ថុរបស់ពួកគេ និងអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុរបស់ពួកគេ។

ការវិនិច្ឆ័យ និងមតិដែលបានលើកឡើងនៅក្នុងឯកសារនេះ គឺបានមកពីគ្រឹះស្ថានដែលជាដៃគូនៃគម្រោង BALANCE និងគ្រឹះស្ថានឧត្តមសិក្សាទាំងឡាយណា ដែលបានសម្រេចចិត្ត ផ្តល់ជាតុចូលនៅក្នុងដំណើរការបង្កើតឯកសារនេះ។

# ឯកសារយោង

MoYES (2019), *Education Strategic Plan 2019-2023*

MoYES (2019*), Cambodia's Education 2030 Road Map*

MoEYS (2021), *Highere Education Sub-sector Strategy 2021-2030*

Ngoy, M., Say, S., Leang, U., Rinna, B., Sokunthy, C., Sovansophal, K. (2019) *Finance in Public Higher Education in Cambodia*. CDRI Working Paper Series No. 115. Phnom Penh.

Say S. (2018), *Higher Education Governance in Cambodia*: An Update, Researchgate Publications.

Say S. – Bunry R. (2021), *Cambodian Public HE in 2040: potential scenarios and the need for transformative leadership*, WP series n. 01/2021 The HEAD Foundation.

Sovannara, K. (2019) *The road to autonomous University in Cambodia: a case study of the National University of Management*. NUM.

Vutha Ros – Koemhong Sol (2021), *The quest for world-class universities: A goal for Cambodian universities?*, in "Cambodian Journal of Educational Research" 2021.

World Bank Group (2019), *Comparing the effectiveness of public finance in Cambodia. A public expenditure review*.



Co-funded by the Erasmus+ Programme of the European Union

Balance

Towards Sustainable Financial Management of Cambodian Universities

# សៀវភៅ-ស

## ស្តីពីគំរូហិរញ្ញវត្ថុ
## សម្រាប់វិស័យអប់រំឧត្តមសិក្សាកម្ពុជា

D4.1.1

Co-funded by the Erasmus+ Programme of the European Union